# II - ឯកសារគណៈរដ្ឋមន្ត្រី

## ១_អនុក្រឹត្យ

ភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៣២ អនក្រ.បក**

**ស្តីពីការចាត់តាំង និង ការប្រព្រឹត្តទៅនៃប្រព័ន្ធ**

**សំរបសំរួលផ្ទៃក្នុង ( Internal Coordination Network )**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ករត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០១ សជ ៩៥ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការនៅអាស៊ី–អាគ្នេយ៍
- បានឃើញសំណើរបស់ព្រះរាជាណាចក្រកម្ពុជា សុំចូលជាផ្លូវការ ជាសមាជិកពេញសិទ្ធិរបស់ សមាគមបណ្តាប្រជាជាតិអាស៊ី–អាគ្នេយ៍ ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៩៦
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ :** បង្កើតប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ដែលជាភាសាអង់គ្លេសហៅថា (Internal Coordination Network ) សំរាប់ដឹកនាំ នឹងធ្វើការសំរបសំរួលសកម្មភាពរបស់

ក្រសួងគន្លឹះនានា បានទាន់ពេលវេលា និង មានប្រសិទ្ធភាពទាក់ទងដល់ការចូល និងបំពេញតួនាទីជាសមាជិកពេញសិទ្ធិ របស់អាស៊ាន នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : ប្រព័ន្ធសំរបសំរួលផ្ទៃក្នុងមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១–សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ | សហប្រធាន |
| ២–សម្តេច នាយករដ្ឋមន្ត្រីទី ២ | សហប្រធាន |
| ៣–រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធានប្រចាំការ |
| ៤–ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៥–រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦–រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ៧–រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ៨–ទេសាភិបាលធនាគារជាតិ | សមាជិក |
| ៩–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០–លេខាធិការដ្ឋានជាតិ អាស៊ាន–កម្ពុជា | លេខាធិការ |

**មាត្រា ៣** : ការអញ្ជើញប្រជុំ :

–សមាជិកទាំងឡាយនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុងចូលរួមប្រជុំតាមការអញ្ជើញរបស សហប្រធាន ។

–ក្នុងករណីចាំបាច់ សមាជិកទាំងឡាយនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ចូលរួមប្រជុំ តាមការអញ្ជើញ របស់អនុប្រធានប្រចាំការ ។

–តាមការចាំបាច់ ប្រធាន ឬ អនុប្រធានប្រចាំការ អាចអញ្ជើញប្រធានស្ថាប័ន ក្រសួងពាក់ព័ន្ធចូលរួមកិច្ចប្រជុំ ។

**មាត្រា ៤** : ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង មានសមត្ថកិច្ច និង ភារៈកិច្ចដូចតទៅ :

ក–សំរបសំរួលគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការធ្វើ សមាហរណកម្ម ( Intergration ) សេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និង សេដ្ឋកិច្ចពិភពលោក ។

ខ–ណែនាំស្ថាប័នសំខាន់ៗ អំពីលំនាំសំរបសំរួល និងកិច្ចសហប្រតិបត្តិការជិតស្និទ ក្នុងការចូល អាស៊ាន, AFTA និងគំរោងផ្សេងៗទៀតរបស់អាស៊ានក្នុងគោល

បំណងទាញយកអោយបានជាអតិបរមា នូវផលប្រយោជន៍ពីការចូលអាស៊ាននិង ជៀសវាងនូវផលវិបាកអវិជ្ជមានទាំងឡាយ ។

គ-ពិនិត្យ និង សំរេច វិធានការជាក់ស្តែង កំណត់ការងារជាអទិភាពទាំងឡាយទាក់ទងដល់ការងារខាងលើ ។

ឃ-ធានាសំរបសំរួលទូទាំងប្រទេសអោយបានឆាប់រហ័សទាន់ពេលវេលា និង មានប្រសិទ្ធភាព ចំពោះរាល់កិច្ចការទាំងឡាយដែលពាក់ព័ន្ធនិងបញ្ហាអាស៊ាន ។

ង-តៀងគរជំនួយទាំងឡាយព្រមទាំងប្រមូលធនធានមនុស្ស និងថវិកាចាំបាច់ដើម្បីជួយឧបត្ថម្ភកិច្ចដំណើរការនៃការចូលជាសមាជិក ពេញសិទ្ធិរបស់អាស៊ានរបស់ព្រះរាជាណាចក្រកម្ពុជា ។

ច-តាមដានត្រួតពិនិត្យ និង វាយតម្លៃរាល់សកម្មភាពទាំងអស់ទាក់ទងនឹងសមាជិកភាព អាស៊ាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥** : ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ប្រើប្រាស់លេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា ស្ថិតក្នុងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសេនាធិការ និងជាយន្តការការងារប្រចាំថ្ងៃរបស់ខ្លួន ។

**មាត្រា ៦** : លេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា មានតួនាទី និងភារៈកិច្ចដូចតទៅ :

ក-ជាអ្នកសំរបសំរួលទូទាំងប្រទេស និង ជាអ្នកទំនាក់ទំនងអន្តរជាតិ ជាមួយនិងលេខាធិការដ្ឋាន អាស៊ានព្រមទាំងលេខាធិការដ្ឋានជាតិ អាស៊ាន ទាំងអស់ ។

ខ-ជាសេនាធិការ និងជំនួយការជូនប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ដើម្បីដោះស្រាយកិច្ចការទាំងអស់ ដែលពាក់ព័ន្ធបញ្ហាអាស៊ាន ហើយដែលទទួលបានការណែនាំពីប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ។

**មាត្រា ៧** : ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

# តួនាទី
# និងភារកិច្ចនៃក្រសួងសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារអាស៊ាន
# ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិក្រសួង
# សេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិង ក្រសួងពាណិជ្ជកម្ម

* * *

## I – ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ :

ក្រសួងការបរទេសទទួលបន្ទុកនយោបាយរួម និងការទូតរបស់រាជរដ្ឋាភិបាល និងជាអ្នកសំរបសំរួលការងារអាស៊ាន ទូទាំងប្រទេសក្នុងឋានៈជាលេខាធិការដ្ឋានជាតិអាស៊ាន ។

តាមលំនាំរបស់អាស៊ាន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ក្រសួងការបរទេស ASEAN Ministerial Meeting (AMM) ជាកិច្ចប្រជុំសំខាន់បំផុត តាមអាទិភាពនយោបាយបន្ទាប់ពីកិច្ចប្រជុំថ្នាក់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល (ASEAN Summit) ។ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិមានតួនាទី និងភារៈកិច្ចធ្វើសេចក្តីសំរេចនានា ផ្នែកនយោបាយជូនឬជួសរាជរដ្ឋាភិបាល ។ ក្នុងឋានៈនេះ រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ធ្វើការសំរបសំរួលជាមួយរដ្ឋមន្ត្រីនានានៃក្រសួងជំនាញ ដែលពាក់ព័ន្ធនិងសកម្មភាពអាស៊ាន ។ បណ្តារដ្ឋមន្ត្រីនៃក្រសួងជំនាញទាំងអោយនោះត្រូវធ្វើសេចក្តីសំរេចទាំងឡាយដោយពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដើម្បីរក្សាច្រកចេញ ចូលការទូតតែមួយគត (Diplomatic Channel) ។

តាមលំនាំរបស់អាស៊ាន មានតែងតាំងមន្ត្រីជាន់ខ្ពស់ម្នាក់ មានឈ្មោះថា Senior Official នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាមន្ត្រីធានានិរន្តភាព នៃ ការងារទាំងឡាយរបស់ក្រសួង និង ភាពអចិន្ត្រៃយ៍របស់ក្រសួង មានឋានៈខ្ពស់ជាងគេបំផុតក្នុងមុខងារសាធារណៈ (Senior Most Civil Servant) ហើយដែលមិនមែនជាឥស្សរជននយោបាយ (Political Appointee) ទេ គឺអគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីជាន់ខ្ពស់នេះ ទទួលបន្ទុកចូលរួមសន្និសីទមន្ត្រីជាន់ខ្ពស់ Senior Official Meeting ( SOM ) មានសិទ្ធិសំរេចក្នុងការចរចាផ្នែកបច្ចេកទេស ហើយបន្ទាប់មកដាក់ជូនមន្ត្រីការបរទេស និង សហប្រតិបត្តិ ការអន្តរជាតិ និង រាជរដ្ឋាភិបាលធ្វើការសំរេចផ្នែកនយោបាយ ។ ជារួមមន្ត្រី

ជាន់ខ្ពស់ផ្នែកនយោបាយ ( SOM ) ត្រៀមរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី មាន AMM ARF PMC និង JMM ជាដើម ។

នៅក្នុងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានបង្កើតអគ្គនាយកដ្ឋានអាស៊ានមួយដឹកនាំដោយអគ្គនាយកមួយរូប ជំនួយការដោយអគ្គនាយករងពីររូប ។ អគ្គនាយកដ្ឋាននេះមានភារកិច្ចដូច តទៅ :

- ជាអ្នកសំរបសំរួលការងារជាមួយ :

  - លេខាធិការដ្ឋានអាស៊ាននៅហ្សាការតា
  - លេខាធិការជាតិអាស៊ាននៃប្រទេសសមាជិកអាស៊ាន
  - អង្គភាពអាស៊ាន នៃក្រសួងនានា

- ជាលេខាធិការរបស់ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (Internal Coordination Network) ដឹកនាំដោយ សម្តេចនាយករដ្ឋមន្ត្រី ទាំងពីរជាសហប្រធាន ។

**II- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ :**

ទទួលខុសត្រូវការងារនយោបាយសេដ្ឋកិច្ចរួមរបស់រាជរដ្ឋាភិបាល និង រៀបចំថវិកាជាតិសំរាប់សកម្មភាពអាស៊ាន ។

នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានមន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់មួយរូបដែលជាមន្ត្រីរាជការជានានិរន្តភាព នៃការងារទាំងឡាយរបស់ក្រសួង និងភាពអចិន្ត្រៃយ៍របស់ក្រសួងមានឋានៈខ្ពស់បំផុតនៅក្នុងមុខងារសាធារណៈ ដូចជាអគ្គលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិដែរ ។ មន្ត្រីរូបនេះជាអ្នកឯកទេសខាងការងារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលហើយជាអ្នកមានសិទ្ធិសំរេចផ្នែកបច្ចេកទេសក្នុងអង្គប្រជុំ និងការចរចាវិស័យជំនាញសេដ្ឋកិច្ចនានាដូចជា SEOM ជាដើម ហើយបន្ទាប់មកត្រូវដាក់ជូនរដ្ឋមន្ត្រីជំនាញ និង រាជរដ្ឋាភិបាលសំរេចផ្នែកនយោបាយ ។

ទន្ទឹមនឹងនេះ នៅក្នុងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ មានបង្កើតនាយកដ្ឋានអាស៊ានមួយ ។ ក្នុងក្រសួងនេះដែរមានបង្កើតអង្គភាព AFTA មួយដែលមានការចូលរួមពីមន្ត្រីនៃក្រសួងពាក់ព័ន្ធនានា ។ អង្គភាពនេះមានភារកិច្ចសំខាន់ក្នុងការពិភាក្សាលើការកាត់បន្ថយពន្ធគយ លើទំនិញនាំចេញ នាំចូល ការបញ្ចូលទំនិញក្នុងបញ្ជីទាំងឡាយ ដូចមានចែងនៅក្នុង CEPT Scheme ជាមួយប្រទេសដែលមានសមាជិកអាស៊ាន និង លេខាធិការដ្ឋានអាស៊ាន ។ នាយកដ្ឋាននេះត្រូវសហការ យ៉ាងជិតស្និតជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការកំណត់មុខទំនិញនានា ។ ក្រសួងសេដ្ឋកិច្ច

និង ហិរញ្ញវត្ថុ ក៏មានភារៈកិច្ចតាមដានមុខសញ្ញាសហប្រតិបត្តិការថ្មីៗ របស់អាស៊ាន ដូចខាង ផ្នែកសេវាកម្ម (Services) និងតំបន់វិនិយោគសេរីអាស៊ាន ASEAN Free Investment Area-AFIA) ជាដើម ។

**III– ក្រសួងពាណិជ្ជកម្ម** : ទទួលខុសត្រូវលើវិស័យនយោបាយពាណិជ្ជកម្មក្រៅប្រទេស ។

នៅក្រសួងនេះ ក៏ត្រូវបង្កើតនាយកដ្ឋានអាស៊ានមួយដែរ ។ នាយកដ្ឋាននេះត្រូវសហការយ៉ាងជិតស្និទជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការកំណត់មុខទំនិញក្នុង CEPT Scheme ។ ក្រសួងពាណិជ្ជកម្មជាអ្នកចេញ Certificate of Origin (CO) ចូលរួមយ៉ាងសកម្មនៅក្នុងបញ្ហានានា ទាក់ទងដល់កម្មសិទ្ធិបញ្ញា (Intellectual property) ការត្រួតពិនិត្យគុណភាពទំនិញ (Quality control) អាជ្ញាកណ្តាល (arbitration) ការផ្តល់ភាពអនុគ្រោះបំផុត (MFN) និងភាពអនុគ្រោះដូចគ្នានឹងក្រុមហ៊ុនជាតិកម្ពុជា (National treatment) ដល់ក្រុមហ៊ុននានា នៃបណ្តាប្រទេសជាសមាជិកអាស៊ាន ។

ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងមន្ត្រីជាន់ខ្ពស់មួយរូបជា Deputy SEOM ។

**VI– ក្រសួងនិងស្ថាប័នពាក់ព័ន្ធដទៃទៀត** :

ត្រូវបង្កើតអង្គភាពអាស៊ានមួយថ្នាក់ស្មើការិយាល័យហៅឈ្មោះជា ASEAN Unit ដើម្បីវិភាគ និងគ្រប់គ្រងការងារអាស៊ាននានា ដែលទាក់ទិនផ្ទាល់ទៅនឹងសមត្ថកិច្ចនៃក្រសួង ឬស្ថាប័នខ្លួន។

ក្រសួងទាំងនោះចាំបាច់ធ្វើការសំរបសំរួល និង សហប្រតិបត្តិការជិតស្និទ្ធជានិរន្តជាមួយក្រសួងពាណិជ្ជកម្មក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងជាមួយលេខាធិការដ្ឋានជាតិអាស៊ាន ដែលស្ថិតនៅក្នុងក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

ភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

* * *